អេស៊ីលីដា
ACLEDA BANK

# របាយការណ៍ប្រចាំត្រីមាសទី៣

គិតត្រឹមថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១

## ព័ត៌មានហិរញ្ញវត្ថុសង្ខេប

| ស្ថានភាពហិរញ្ញវត្ថុ (គិតជាលានរៀល) | ត្រីមាសទី៣ ឆ្នាំ២០២១ | ឆ្នាំ២០២០ | ឆ្នាំ២០១៩ |
|---|---|---|---|
| ទ្រព្យសកម្មសរុប | ៣០.៥៩៥.៦៨១ | ២៦.៥០០.៧៩៣ | ២៥.១៦៣.៧៨៤ |
| បំណុលសរុប | ២៥.៦៦៥.៤១៤ | ២២.០៩៣.២៥៨ | ២១.២៣៣.៦០៣ |
| មូលធនសរុប | ៤.៩៣០.២៦៧ | ៤.៤០៧.៥៣៥ | ៣.៩៣០.១៨១ |
| **លទ្ធផលហិរញ្ញវត្ថុ (គិតជាលានរៀល)** | **ត្រីមាសទី៣ ឆ្នាំ២០២១** | **ត្រីមាសទី៣ ឆ្នាំ២០២០** | **ត្រីមាសទី៣ ឆ្នាំ២០១៩** |
| ចំណូលសរុប | ៦៥៦.៨៩២ | ៥៨៤.២៤៦ | ៥៨៤.២៦៥ |
| ចំណេញ/(ខាត) មុនបង់ពន្ធ | ១៩៨.៥៣៧ | ១៨០.៦៧១ | ១៤៤.៧៧៦ |
| ចំណេញ/(ខាត) សុទ្ធក្នុងការិយបរិច្ឆេទ | ១៥៨.៦៩៥ | ១៤១.៩៤៦ | ១១៤.៩៦៤ |
| លទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ | ១៦០.០៨៨ | ១៤៣.៧១៧ | ១១៦.៤១២ |
| **អនុបាតហិរញ្ញវត្ថុ (%)** | **ត្រីមាសទី៣ ឆ្នាំ២០២១** | **ឆ្នាំ២០២០** | **ឆ្នាំ២០១៩** |
| អនុបាតសាធនភាព | ២៤,៣២% | ២៥,១៥% | ២៦,៣១% |
| អនុបាតបំណុលធៀបនឹងមូលធន | ៥២០,៥៧% | ៥០១,២៦% | ៥៤០,២៧% |
| អនុបាតក្របខ័ណ្ឌសន្ទនីយភាព | ១៦០,០៦% | ១៤៩,៣១% | ១៦៧,២៧% |
| អនុបាតឥណទានមិនដំណើរការ (*) | ២,៦៤% | ២,៤០% | ១,២៤% |
| អនុបាតឥណទានធៀបនឹងប្រាក់បញ្ញើ | ៩២,៦៤% | ៩៧,៧៣% | ៨៨,៨២% |
| តម្លៃចុះបញ្ជីក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (រៀល) | ១១.៣២៥ | ១០.១៧៥ | ៩.១៦៥ |
| | **ត្រីមាសទី៣ ឆ្នាំ២០២១** | **ត្រីមាសទី៣ ឆ្នាំ២០២០** | **ត្រីមាសទី៣ ឆ្នាំ២០១៩** |
| អនុបាតចំណេញធៀបនឹងទ្រព្យសកម្មមធ្យម (ROAA)(**) | ០,៥៣% | ០,៥៥% | ០,៤៦% |
| អនុបាតចំណេញធៀបនឹងមូលធនមធ្យម (ROAE) (**) | ៣,២៩% | ៣,៣៧% | ៣,០៨% |
| អនុបាតលទ្ធភាពបង់ការប្រាក់ (ដង) | ២,០៩ | ២,១៨ | ១,៨៦ |
| ចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (រៀល) | ៣៦៦,៧៤ | ៣២៧,៧០ | ២៦៨,០៩ |
| ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ | គ្មាន | គ្មាន | គ្មាន |
| អនុបាតហិរញ្ញវត្ថុសំខាន់ៗផ្សេងទៀត | គ្មាន | គ្មាន | គ្មាន |

(*) ឥណទានមិនដំណើរការ = ឥណទាននៅដំណាក់កាលទី៣

(**) . អនុបាតទាំងនេះមិនមែនជាអនុបាតប្រចាំឆ្នាំនោះទេ ហើយត្រូវបានគណនាដោយប្រើតួលេខប្រាក់ចំណេញដែលផ្តល់ជូនដល់ភាគហ៊ុនិករបស់ធនាគាររយៈពេល ៣ខែ ចាប់ពីថ្ងៃទី០១ ខែកក្កដា ដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១។

. ចំណេញធៀបនឹងមូលធនមធ្យម = ប្រាក់ចំណេញដែលផ្តល់ជូនដល់ភាគហ៊ុនិករបស់ធនាគារ / មូលធនសរុបមធ្យមរបស់ភាគហ៊ុនិករបស់ធនាគារ

# ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប







អនុបាតហិរញ្ញវត្ថុ(%)
៥២០,៥៧%
៥៤០,២៧%
៥០១,២៦%
១៦០,០៦%
១៦៧,២៧%
១៤៩,៣១%
២៦,៣១%
២៥,១៥%
២៤,៣២%
២,៦៤%
២,៤០%
១,២៤%
៩៧,៧៣%
៩២,៦៤%
៨៨,៨២%
អនុបាតសាធនភាព
អនុបាតបំណុលធៀប នឹងមូលធន
អនុបាតក្រុបខ័ណ្ឌ សន្ទនីយភាព
អនុបាតឥណទាន មិនដំណើរការ
អនុបាតឥណទានធៀប នឹងប្រាក់បញ្ញើ
ត្រីមាសទី៣ ឆ្នាំ២០២១
ឆ្នាំ២០២០
ឆ្នាំ២០១៩


៣,២៩%
៣,៣៧%
៣,០៨%
០,៥៣%
០,៥៥%
០,៤៦%
អនុបាតចំណេញធៀបនឹងទ្រព្យសកម្មមធ្យម (ROAA)
អនុបាតចំណេញធៀបនឹងមូលធនមធ្យម (ROAE)
ត្រីមាសទី៣ ឆ្នាំ២០២១
ត្រីមាសទី៣ ឆ្នាំ២០២០
ត្រីមាសទី៣ ឆ្នាំ២០១៩


ចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (រៀល)
២៦៨,០៩
៣២៧,៧០
៣៦៦,៧៤
ត្រីមាសទី៣ ឆ្នាំ២០១៩
ត្រីមាសទី៣ ឆ្នាំ២០២០
ត្រីមាសទី៣ ឆ្នាំ២០២១
ត្រីមាសទី៣ ឆ្នាំ២០១៩
ត្រីមាសទី៣ ឆ្នាំ២០២០
ត្រីមាសទី៣ ឆ្នាំ២០២១


តម្លៃចុះបញ្ជីក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (រៀល)
៩.១៦៥
១០.១៧៥
១១.៣២៥
ឆ្នាំ២០១៩
ឆ្នាំ២០២០
ត្រីមាសទី៣ ឆ្នាំ២០២១
ឆ្នាំ២០១៩
ឆ្នាំ២០២០
ត្រីមាសទី៣ ឆ្នាំ២០២១

## សមាសភាពក្រុមប្រឹក្សាភិបាល



**លោក ឆាយ សឿន**
*ប្រធានក្រុមប្រឹក្សាភិបាល*



**បណ្ឌិត អ៊ុន ចាន់នី**
*អភិបាលប្រតិបត្តិ*



**លោក រ័ត្ន យូម៉េង**
*អភិបាលប្រតិបត្តិ*



**លោក Stéphane Mangiavacca**
*អភិបាលមិនប្រតិបត្តិ*



**លោក Kenichiro Mori**
*អភិបាលមិនប្រតិបត្តិ*



**លោក Albertus Bruggink**
*អភិបាលមិនប្រតិបត្តិ*



**លោក កាយ ឡូត**
*អភិបាលមិនប្រតិបត្តិ*



**លោក Pieter Kooi**
*អភិបាលឯករាជ្យ*



**លោក វ៉ាន់ ស៊ូអៀង**
*អភិបាលឯករាជ្យ*

# សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល

តាងនាមឲ្យធនាគារ អេស៊ីលីដា ភីអិលស៊ី (“ធនាគារ”) និងក្រុមប្រឹក្សាភិបាល ខ្ញុំបាទមានកិត្តិយស និងសេចក្តីសោមនស្សរីករាយ សូមផ្តល់ជូននូវរបាយការណ៍ហិរញ្ញវត្ថុប្រចាំត្រីមាសទី៣ ឆ្នាំ២០២១ របស់ធនាគារ គិតចាប់ពីថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២១ ដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១។

ការឆ្លងជំងឺកូវីដ-១៩ ជាពិសេសមេរោគបំប្លែងថ្មី "ដែលតា" ចូលក្នុងសហគមន៍ បានបង្កនូវក្តីព្រួយបារម្ភយ៉ាងខ្លាំងដល់រាជរដ្ឋាភិបាល ក៏ដូចជាប្រជាជននៅកម្ពុជា។ ដូច្នេះ រាជរដ្ឋាភិបាលនៅតែរក្សាអនុវត្តនូវវិធានការការពារដ៏មានប្រសិទ្ធភាព ជាពិសេសយុទ្ធនាការចាក់វ៉ាក់សាំងដូសជំរុញជូនសាធារណជនទូទៅ និងការពន្លឿនចាក់វ៉ាក់សាំងជូនកុមារ និងយុវជន ដែលមានអាយុចាប់ពី៦ឆ្នាំ ដល់១៧ឆ្នាំ ដើម្បីការពារ និងកាត់បន្ថយការឆ្លង ក៏ដូចជាស្តារ និងជំរុញកំណើនសេដ្ឋកិច្ច។ ធនាគារនៅតែបន្តអនុវត្តវិធានការការពារការឆ្លង ដើម្បីធានានូវសុខភាព និងសុវត្ថិភាពជូនកម្មករនិយោជិត តាមរយៈការផ្តល់ជូនពួកគាត់នូវការធ្វើតេស្តរហ័សស្វែងរកមេរោគ មុននឹងចូលធ្វើការនៅការិយាល័យ និងអនុវត្តការងារពីចម្ងាយ ដោយកម្មករនិយោជិតយ៉ាងហោច៥០% នៃកម្មករនិយោជិតទាំងអស់នៅក្នុងនាយកដ្ឋាន និងការិយាល័យនីមួយៗ តាមរយៈការផ្លាស់វេនគ្នាក្នុងមួយសប្តាហ៍ម្តង ដើម្បីរក្សាប្រតិបត្តិការរបស់ធនាគារឲ្យដំណើរការដោយរលូន និងប្រកបដោយសុវត្ថិភាព។

ដើម្បីឆ្លើយតបនឹងយុទ្ធសាស្ត្ររបស់ខ្លួន ធនាគារបានកែលម្អ និងធ្វើនវានុវត្តលើ **អេស៊ីលីដាម៉ូបាល** ដើម្បីឆ្លើយតបនឹងតម្រូវការរបស់អតិថិជន និងការប្រកួតប្រជែងទីផ្សារនៅក្នុងស្ថានភាពនៃការឆ្លងជំងឺកូវីដ-១៩។ នៅក្នុងអំឡុងត្រីមាសទី៣នៃឆ្នាំ២០២១នេះ ធនាគារ បានអភិវឌ្ឍ កែលម្អ និងដាក់ឲ្យដំណើរការបន្ថែមនូវមុខងារថ្មីៗជាច្រើននៅក្នុង **អេស៊ីលីដាម៉ូបាល** ដែលមានដូចជា ទទួលបានប្រាក់កម្ចីភ្លាមៗ បើកគណនីធនាគារ និងគណនីប្រាក់បញ្ញើមានកាលកំណត់ បង្កើតប័ណ្ណនិម្មិត បង់ពន្ធលើអចលនទ្រព្យ និងយានយន្តគ្រប់ប្រភេទ ទាញយករបាយការណ៍គណនីសង្ខេប ។ល។ ទន្ទឹមនឹងនេះ ធនាគារបាន និងកំពុងតែពង្រីក **ទីតាំងសេវាកម្មធនាគារស្វ័យប្រវត្តិ** នៅតាមបណ្តាតំបន់សក្តានុពលនានាទូទាំងប្រទេស បន្ថែមលើសាខា និងការិយាល័យដែលមានស្រាប់ ដោយបំពាក់នូវម៉ាស៊ីនអេធីអឹមដកប្រាក់ ម៉ាស៊ីនអេធីអឹមដាក់-ដកប្រាក់ ម៉ាស៊ីនបើកគណនី និងបោះពុម្ពប័ណ្ណអេធីអឹម និងម៉ាស៊ីនដាក់ប្រាក់បញ្ញើមានកាលកំណត់ ដែលមានបច្ចេកវិទ្យាចុងក្រោយ និងសុវត្ថិភាពខ្ពស់ ដើម្បីបង្កភាពងាយស្រួលជូនអតិថិជនក្នុងការធ្វើ **ស្វ័យប្រតិបត្តិការសេវាកម្មធនាគារ** ដែលរួមមានដូចជា ការដាក់ប្រាក់ ការដកប្រាក់ ការផ្ទេរប្រាក់ ការប្តូរប្រាក់ ការទូទាត់វិក្កយបត្រ ការបង្កើតប័ណ្ណអេធីអឹម ការផ្លាស់ប្តូរព័ត៌មានគណនី ការដាក់ប្រាក់បញ្ញើមានកាលកំណត់ ការបោះពុម្ពវិញ្ញាបនបត្រប្រាក់បញ្ញើ និងស្វ័យសេវាកម្មជាច្រើនទៀត។ ព្រមជាមួយគ្នានេះ **ម៉ាស៊ីនឆូតកាតអេស៊ីលីដា** និង**ឃ្យូអរកូដ** ក៏ត្រូវបានដាក់បន្ថែមនៅតាមបណ្តាស្ថាប័ន ក្រុមហ៊ុន ផ្សារ ហាង តូបអាជីវកម្ម និងដៃគូអាជីវកម្មជាច្រើនទៀត ដើម្បីជំនួយអតិថិជនក្នុងការទូទាត់ថ្លៃទំនិញ-សេវាកម្មដោយផ្ទាល់ និង/ឬតាមអនឡាញ។

នៅក្នុងអំឡុងត្រីមាសនេះ ធនាគារសម្រេចបាននូវលទ្ធផលជាវិជ្ជមានដូចខាងក្រោម៖

គិតត្រឹមថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១ ប្រាក់បញ្ញើសរុបបានកើនឡើងចំនួន ៨២៧,៩៨ លានដុល្លារអាមេរិក ហើយសមតុល្យឥណទានសរុបបានកើនឡើងចំនួន ៥៣២,០៩ លានដុល្លារអាមេរិក បើធៀបនឹងដំណាច់ឆ្នាំ២០២០។ ប្រសិនបើធៀបនឹងដំណាច់ខែកញ្ញា ឆ្នាំ២០២០ ប្រាក់បញ្ញើសរុប និងសមតុល្យឥណទានសរុបបានកើនឡើងចំនួន ៩១៣,២១ លានដុល្លារអាមេរិក (២០,១៨%) និង ៨៩៤,៧៣ លានដុល្លារអាមេរិក (២១,៥៩%) តាមលំដាប់។

ធនាគារទទួលបានប្រាក់ចំណេញដែលផ្តល់ជូនដល់ភាគហ៊ុនិករបស់ធនាគារចំនួន ៣៨,៩៦ លានដុល្លារអាមេរិក ដោយកើនឡើង ១២,៥៥% ស្មើនឹង ៤,៣៤ លានដុល្លារអាមេរិក បើធៀបនឹងត្រីមាសទី៣ដូចគ្នា ក្នុងឆ្នាំ២០២០។ សម្រាប់ត្រីមាសទី៣ ឆ្នាំ២០២១នេះ ធនាគារទទួលបានអនុបាតចំណេញធៀបនឹងទ្រព្យសកម្មមធ្យមចំនួន ០,៥៣% និងទទួលបានអនុបាតចំណេញធៀបនឹងមូលធនមធ្យមចំនួន ៣,២៩%។

ជាទីបញ្ចប់ យើងខ្ញុំសូមថ្លែងអំណរគុណ និងសំដែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅ ចំពោះភាគីពាក់ព័ន្ធ អតិថិជន និងជាពិសេសអាជ្ញាធរពាក់ព័ន្ធទាំងអស់ ដែលបានបន្តការជ្រោមជ្រែង និងការគាំទ្រដល់ធនាគារ។

ថ្ងៃសុក្រ ១កើត ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០២១
ហត្ថលេខា និងត្រា

ធនាគារ អេស៊ីលីដា ភីអិលស៊ី
ACLEDA BANK PLC.

**ឆាយ សឿន**

# មាតិកា


ព័ត៌មានហិរញ្ញវត្ថុសង្ខេប ..... i

ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប ..... ii

សមាសភាពក្រុមប្រឹក្សាភិបាល ..... v

សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល ..... vi

**ផ្នែកទី១- ព័ត៌មានទូទៅពាក់ព័ន្ធនឹងបុគ្គលចុះបញ្ជីលក់មូលបត្រ ..... ១**

**ក- អត្តសញ្ញាណបុគ្គលចុះបញ្ជីលក់មូលបត្រ ..... ១**

**ខ- លក្ខណៈនៃធុរកិច្ច ..... ១**

**គ- ព្រឹត្តិការណ៍សំខាន់ៗប្រចាំត្រីមាសរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ ..... ១**

**ផ្នែកទី២- ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច ..... ២**

**ក- លទ្ធផលប្រតិបត្តិការធុរកិច្ច ដោយរួមបញ្ចូលព័ត៌មានធុរកិច្ចតាមផ្នែក ..... ២**

**ខ- រចនាសម្ព័ន្ធចំណូល ..... ៤**

**ផ្នែកទី៣- របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មដោយសវនករឯករាជ្យ ..... ៥**

**ផ្នែកទី៤- ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង ..... ៦**

**ក- ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ ..... ៦**

**ខ- កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ ..... ៩**

**គ- ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល ..... ១០**

**ឃ- ផលប៉ះពាល់នៃការប្តូររូបិយប័ណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ ..... ១០**

**ង- ផលប៉ះពាល់នៃអតិផរណា ..... ១១**

**ច- គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុ របស់រាជរដ្ឋាភិបាល ..... ១១**

**ហត្ថលេខាអភិបាលរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ ..... ១៣**

## ផ្នែកទី១- ព័ត៌មានទូទៅពាក់ព័ន្ធនឹងបុគ្គលចុះបញ្ជីលក់មូលបត្រ

### ក- អត្តសញ្ញាណបុគ្គលចុះបញ្ជីលក់មូលបត្រ

| | |
|---|---|
| ឈ្មោះក្រុមហ៊ុនជាអក្សរខ្មែរ | **ធនាគារ អេស៊ីលីដា ភីអិលស៊ី** |
| ជាអក្សរឡាតាំង | **ACLEDA Bank Plc.** |
| លេខកូដស្តង់ដារ | KH១០០០១០០០០៣ |
| ទីស្នាក់ការ | អគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា |
| លេខទូរស័ព្ទ | +៨៥៥ (០)២៣ ៩៩៨ ៧៧៧ / ៤៣០ ៩៩៩ |
| លេខទូរសារ | +៨៥៥ (០)២៣ ៤៣០ ៥៥៥ |
| គេហទំព័រ | www.acledabank.com.kh |
| អ៊ីម៉ែល | acledabank@acledabank.com.kh |
| លេខវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម | ០០០០៣០៧៧ ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០០០ ចេញដោយក្រសួងពាណិជ្ជកម្ម |
| លេខអាជ្ញាបណ្ណអាជីវកម្ម | ០៦ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៦ ចេញដោយ ធនាគារជាតិ នៃ កម្ពុជា |
| សេចក្តីសម្រេចអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មាន | លេខ០៥៣/២០គ.ម.ក./ស.ស.រ. ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២០ ចេញដោយ គណៈកម្មការមូលបត្រកម្ពុជា បច្ចុប្បន្នជា និយ័តករមូលបត្រកម្ពុជា (“ន.ម.ក.”) |
| ឈ្មោះបុគ្គលតំណាងបុគ្គលចុះបញ្ជីលក់មូលបត្រ | **បណ្ឌិត អ៊ិន ចាន់នី** |

### ខ- លក្ខណៈនៃធុរកិច្ច

ធនាគារ អេស៊ីលីដា ភីអិលស៊ី គឺជាធនាគារពាណិជ្ជដែលមានសាខា និងបណ្តាញការិយាល័យធំជាងគេបង្អស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ធនាគារបានចុះបញ្ជីនៅក្នុង ផ.ម.ក. ចាប់តាំងពីថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២០។ បច្ចុប្បន្ននេះធនាគារមានក្រុមហ៊ុនបុត្រសម្ព័ន្ធចំនួន៤ រួមមាន៖ (១) ធនាគារ អេស៊ីលីដា ឡាវ លីមីតធីត (២) ស្ថាប័នមីក្រូហិរញ្ញវត្ថុ អេស៊ីលីដា មីយ៉ាន់ម៉ា (៣) ក្រុមហ៊ុន អេស៊ីលីដា ស៊ីឃ្យូរីធី ភីអិលស៊ី និង (៤) វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ព្រមទាំងមានការិយាល័យតំណាងចំនួន១នៅប្រទេសមីយ៉ាន់ម៉ា។

### គ- ព្រឹត្តិការណ៍សំខាន់ៗប្រចាំត្រីមាសរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ

ក្នុងអំឡុងត្រីមាសនេះ ធនាគារ អេស៊ីលីដា ភីអិលស៊ី បានអភិវឌ្ឍ កែលម្អ និងដាក់ឲ្យដំណើរការនូវមុខងារថ្មីៗ ជាច្រើន នៅក្នុងកម្មវិធី **អេស៊ីលីដាម៉ូបាល** ដែលមានដូចខាងក្រោម៖

- ទទួលបានប្រាក់កម្ចីភ្លាមៗ
- បើកគណនីធនាគារ និងគណនីប្រាក់បញ្ញើមានកាលកំណត់
- បង្កើតប័ណ្ណនិម្មិត
- បង់ពន្ធលើអចលនទ្រព្យ និងយានយន្តគ្រប់ប្រភេទ
- ទាញយករបាយការណ៍គណនីសង្ខេប

- ទាញយកកាលវិភាគបង់ប្រាក់
- បង់ប្រាក់សំណងឥណទានរបស់ស្ថាប័នហិរញ្ញវត្ថុ
- ទទួលសារជូនដំណឹងពេលទទួលប្រាក់ពីអ្នកទិញ
- បង់បុព្វលាភធានារ៉ាប់រង
- ភ្ជាប់គណនីបាគង
- កំណត់ឈ្មោះគណនីធនាគារ
- បន្ថែមគោលបំណងលើប្រតិបត្តិការផ្ទេរប្រាក់រវាងគណនីផ្ទាល់ខ្លួន
- ផ្ញើសារជូនដំណឹងឲ្យរក្សាទុកសមតុល្យគណនីសម្រាប់ទូទាត់ប្រាក់សំណងឥណទាន
- ដាក់ចំណាត់ថ្នាក់លើកម្មវិធីអេស៊ីលីដាម៉ូបាល
- ទូទាត់វិក្កយបត្ររបស់គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ។ល។

សម្រាប់ព័ត៌មានលម្អិតបន្ថែមអំពីមុខងារនីមួយៗ ខាងលើនេះ សូមចូលទៅកាន់តំណភ្ជាប់៖
https://www.acledabank.com.kh/qr/toanchet

## ផ្នែកទី២- ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច

### ក- លទ្ធផលប្រតិបត្តិការធុរកិច្ច ដោយរួមបញ្ចូលព័ត៌មានធុរកិច្ចតាមផ្នែក

- **ប្រតិបត្តិការក្នុងវិស័យធនាគារ**

  ត្រឹមដំណាច់ខែកញ្ញា ឆ្នាំ២០២១ ធនាគារពាណិជ្ជមានចំនួន៥៤ (ធនាគារក្នុងស្រុកចំនួន២៤ បុត្រសម្ព័ន្ធធនាគារបរទេសចំនួន១៨ និងសាខាធនាគារបរទេសចំនួន១២) ធនាគារឯកទេសចំនួន១០ (ធនាគារក្នុងស្រុកចំនួន០៤ និងធនាគារបរទេសចំនួន០៦) គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន៨៣ (គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើចំនួន០៦ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើចំនួន៧៧) ក្រុមហ៊ុនភតិសន្យាចំនួន១៧ ការិយាល័យតំណាងធនាគារបរទេសចំនួន០៦ គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ចំនួន២៨ និងគ្រឹះស្ថានឥណទានជនបទចំនួន២៨៣ ។ (Source: NBC Report, CMA Report, and Actually Updated)

- **ប្រតិបត្តិការអាជីវកម្ម និងចំណែកទីផ្សាររបស់ធនាគារ អេស៊ីលីដា នៅក្នុងវិស័យធនាគារ:**

  ធនាគារ អេស៊ីលីដា ភីអិលស៊ី មានចំណែកទីផ្សារ ១៥,៥៩% និង ១៣,៦៦% រៀងគ្នាសម្រាប់ប្រាក់បញ្ញើ និងកម្ចីឥណទានគិតត្រឹមដំណាច់ខែកក្កដា ឆ្នាំ២០២១។

  គិតនៅត្រឹមដំណាច់ខែកញ្ញា ឆ្នាំ២០២១ ធនាគារ អេស៊ីលីដា និងក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ខ្លួនទទួលបានលទ្ធផលសំខាន់ៗ ដូចខាងក្រោម៖

| លទ្ធផលសំខាន់ៗ | លទ្ធផលសម្រេចបាន | | |
|---|---|---|---|
| | ត្រីមាសទី៣ ឆ្នាំ២០២១ | ឆ្នាំ២០២០ | ឆ្នាំ២០១៩ |
| **សេវាឥណទាន** | | | |
| ចំនួនឥណទានសកម្ម | ៥៣៨.២៥៥ | ៥៥៥.៣២៣ | ៥៣៦.៨៩១ |
| សមតុល្យឥណទានសរុប (លានរៀល) | ២០.៥៥២.៩៨៣ | ១៨.២២៩.៣៧២ | ១៥.៨០៨.៨១៤ |
| **សេវាបញ្ញើ-សន្សំ** | | | |
| ចំនួនគណនីសរុប | ៣.១៦៧.២២៨ | ២.៨៩៤.៩០៧ | ២.៦២០.៧៧៨ |
| ចំនួនទឹកប្រាក់សរុប (លានរៀល) | ២២.១៨៦.៨១០ | ១៨.៦៥២.៦៩០ | ១៧.៧៩៩.១៨៤ |

| លទ្ធផលសំខាន់ៗ | លទ្ធផលសម្រេចបាន | | |
|---|---|---|---|
| | ត្រីមាសទី៣ ឆ្នាំ២០២១ | ឆ្នាំ២០២០ | ឆ្នាំ២០១៩ |
| **សេវាធនាគារអេឡិចត្រូនិក** | | | |
| **បណ្ណអេធីអឹមអេស៊ីលីដា** | | | |
| ចំនួនបណ្ណបោះផ្សាយសរុប | ១.៥១៣.៥១៨ | ១.៣៩៦.៧៧៨ | ១.២៧៧.៧២៥ |
| ចំនួនប្រតិបត្តិការសរុប | ១៤.៤១១.៩៤១ | ១៩.៧៦៨.២២៣ | ២០.៤០៣.២០០ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ១២.០០០.៧៥៣ | ១៣.៧៧៥.៩១៨ | ១២.៥៤៨.០៦៦ |
| **អេស៊ីលីដាម៉ូបាល** | | | |
| ចំនួនអ្នកប្រើប្រាស់សរុប | ២.១៦២.៨៥១ | ១.៧៨២.៨១៤ | ១.២៧៦.៥២៨ |
| ចំនួនប្រតិបត្តិការសរុប | ៥៤.៤៣៧.០៦៨ | ៤៨.៧៤៩.៥៩៩ | ២៨.២៦៤.៩៧២ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ៧៨.៩០៧.៨០៧ | ៥៩.២១១.២៧៩ | ៣៧.៣០៣.១៣៧ |
| **អេស៊ីលីដាអ៊ីនធើណែត** | | | |
| ចំនួនអ្នកប្រើប្រាស់សរុប | ១៣.០៥៦ | ១១.៦៧៩ | ១១.៣៣១ |
| ចំនួនប្រតិបត្តិការសរុប | ៩៧៩.១៦១ | ៨៨៦.៩៩០ | ៥១០.២៩៧ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ១៣.៥៦៧.០៦០ | ១១.២៨៥.៩៤៨ | ៥.២៣៥.៦១៦ |
| **អេស៊ីលីដាអ៊ីខមមើស** | | | |
| ចំនួនដៃគូអាជីវកម្មសរុប | ៥៩ | ៥១ | ៤៨ |
| ចំនួនប្រតិបត្តិការសរុប | ២.២៧៤.២៤៤ | ៤៤៧.៩២៩ | ៤៦៧.៦៦៨ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ៨៤៨.៧៦៨ | ៣៦០.០០០ | ២១៣.២៦២ |
| **ម៉ាស៊ីនអេធីអឹមអេស៊ីលីដា** | | | |
| ចំនួនម៉ាស៊ីនសរុប | ៩២៥ | ៧៩០ | ៦៨៣ |
| ចំនួនប្រតិបត្តិការសរុប | ១៩.៧៥៩.៩៣៨ | ២៦.៥៧៤.៦៧៨ | ២៤.១៨១.២៣១ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ១៩.៥០៧.៧៨៣ | ២០.១៩៨.៧២៤ | ១៥.៩២៩.១៩៧ |
| **ម៉ាស៊ីនឆូតកាតអេស៊ីលីដា** | | | |
| ចំនួនម៉ាស៊ីនឆូតកាតសរុប | ៤.៣៥៧ | ៤.២៨៧ | ៤.២៨៩ |

| លទ្ធផលសំខាន់ៗ | លទ្ធផលសម្រេចបាន | | |
|---|---|---|---|
| | ត្រីមាសទី៣ ឆ្នាំ២០២១ | ឆ្នាំ២០២០ | ឆ្នាំ២០១៩ |
| ចំនួនប្រតិបត្តិការសរុប | ១.៣៥៦.៦៣៣ | ២.៤៥៧.៦២៦ | ២.៤១២.៩៣៨ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ៣៣០.០៦២ | ៦៥៧.៥០៦ | ៨៤៩.៣៩២ |
| **កូដ QR នៅតាមហាងទំនិញនានា** | | | |
| ចំនួនពាណិជ្ជករបំពាក់កូដ QR | ១១១.១២០ | ៦៣.៧១៤ | ៣០.៩៨៩ |
| ចំនួនប្រតិបត្តិការសរុប | ២.០៦១.៥៦១ | ១.៨៤២.៩១៣ | ៧៣៥.៣១២ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ៣៦៨.៤៨០ | ១៨៦.៦៩១ | ៩០.៨៨៦ |
| **បណ្តាញប្រតិបត្តិការ និង បុគ្គលិក** | | | |
| **ធនាគារ អេស៊ីលីដា ភីអិលស៊ី** | | | |
| ចំនួនការិយាល័យសរុប | ២៦២ | ២៦៣ | ២៦២ |
| ចំនួនធនាគារស្វ័យប្រវត្តិ | ១៧ | ០ | ០ |
| ចំនួនបុគ្គលិកសរុប | ១២.០៨៨ | ១២.០១៣ | ១១.៩៩៧ |
| **ក្រុមហ៊ុនបុត្រសម្ព័ន្ធ (ក្នុង និង ក្រៅប្រទេស)** | | | |
| ចំនួនការិយាល័យសរុប | ៥៧ | ៥៦ | ៥៣ |
| ចំនួនបុគ្គលិកសរុប | ១.៦២៨ | ១.៦៩១ | ១.៦៥៨ |

## ខ- រចនាសម្ព័ន្ធចំណូល

| ល.រ | ប្រភពចំណូល (លានរៀល) | ត្រីមាសទី៣ ឆ្នាំ២០២១ | | ត្រីមាសទី៣ ឆ្នាំ២០២០ | | ត្រីមាសទី៣ ឆ្នាំ២០១៩ | |
|---|---|---|---|---|---|---|---|
| | | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| ១ | ចំណូលការប្រាក់ | ៥៩៥.៣៦៨ | ៩០,៦៣% | ៥២៣.៥១១ | ៨៩,៦០% | ៥១១.២៩០ | ៨៧,៥១% |
| ២ | ចំណូលកម្រៃ និងជើងសា | ៤២.៦៧៥ | ៦,៥០% | ៤៦.៥៤៨ | ៧,៩៧% | ៥០.៨៦៨ | ៨,៧១% |
| ៣ | ចំណូលផ្សេងៗ | ១៨.៨៤៩ | ២,៨៧% | ១៤.១៨៧ | ២,៤៣% | ២២.១០៧ | ៣,៧៨% |
| **ចំណូលសរុប** | | **៦៥៦.៨៩២** | **១០០%** | **៥៨៤.២៤៦** | **១០០%** | **៥៨៤.២៦៥** | **១០០%** |

សូមពិនិត្យមើលឧបសម្ព័ន្ធដែលបានភ្ជាប់មកជាមួយ
របាយការណ៍ហិរញ្ញវត្ថុដែលត្រូវបានធ្វើសវនកម្មដោយសវនករឯករាជ្យ

## ផ្នែកទី៤- ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង

ការពិភាក្សា និងការវិភាគខាងក្រោមនេះផ្តោតសំខាន់លើលទ្ធផលប្រតិបត្តិការ និងលទ្ធផលហិរញ្ញវត្ថុដោយផ្អែកលើរបាយការណ៍ហិរញ្ញវត្ថុចន្លោះពេលគិតត្រឹមថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១ ដែលត្រូវបានធ្វើសវនកម្មដោយសវនករឯករាជ្យ។ របាយការណ៍ហិរញ្ញវត្ថុចន្លោះពេលត្រូវបានរៀបចំឡើងដោយអនុលោមតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា(ស.រ.ហ.អ.ក)។ មានតែសមាសធាតុសំខាន់ៗនៃរបាយការណ៍ហិរញ្ញវត្ថុ និងកត្តាសំខាន់ៗដែលប៉ះពាល់ដល់ប្រាក់ចំណេញរបស់ធនាគារប៉ុណ្ណោះត្រូវបានយកមកធ្វើការពិភាក្សា និងវិភាគ។

## ក- ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ

### ១- ការវិភាគចំណូល

ធនាគារ អេស៊ីលីដា ភីអិលស៊ី មានប្រភពចំណូលធំៗចំនួនបីគឺ ចំណូលការប្រាក់ ចំណូលកម្រៃនិងជើងសា និងចំណូលផ្សេងៗ។

- ចំណូលការប្រាក់៖ រួមមានចំណូលការប្រាក់ពីឥណទាននិងបុរេប្រទាន ចំណូលការប្រាក់ពីប្រាក់បញ្ញើនៅធនាគារផ្សេងៗ និងការវិនិយោគហិរញ្ញវត្ថុ។
- ចំណូលកម្រៃ និងជើងសា៖ រួមមានកម្រៃជើងសា កម្រៃជើងសាបានពីភ្នាក់ងារធានារ៉ាប់រង កម្រៃពីម៉ាស៊ីនអេធីអឹម កម្រៃពីការសងឥណទានមុនកាលកំណត់ កម្រៃពីសេវាប្រាក់បញ្ញើ កម្រៃពីសេវាធានា និងកម្រៃពីការបណ្តុះបណ្តាល។
- ចំណូលផ្សេងៗ៖ រួមមានចំណេញពីការប្តូររូបិយប័ណ្ណ ចំណេញពីការលក់ទ្រព្យនិងបរិក្ខារ ភាគលាភលើការវិនិយោគហិរញ្ញវត្ថុ និងចំណូលផ្សេងៗ។

### ២- ការវិភាគចំណូលតាមផ្នែក

| ល.រ | ប្រភពចំណូល (លានរៀល) | ត្រីមាសទី៣ ឆ្នាំ២០២១ | | ត្រីមាសទី៣ ឆ្នាំ២០២០ | | ត្រីមាសទី៣ ឆ្នាំ២០១៩ | |
|---|---|---|---|---|---|---|---|
| | | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| ១ | ចំណូលការប្រាក់ | ៥៩៥.៣៦៨ | ៩០,៦៣% | ៥២៣.៥១១ | ៨៩,៦០% | ៥១១.២៩០ | ៨៧,៥១% |
| ២ | ចំណូលកម្រៃ និងជើងសា | ៤២.៦៧៥ | ៦,៥០% | ៤៦.៥៤៨ | ៧,៩៧% | ៥០.៨៦៨ | ៨,៧១% |
| ៣ | ចំណូលផ្សេងៗ | ១៨.៨៤៩ | ២,៨៧% | ១៤.១៨៧ | ២,៤៣% | ២២.១០៧ | ៣,៧៨% |
| | **ចំណូលសរុប** | **៦៥៦.៨៩២** | **១០០%** | **៥៨៤.២៤៦** | **១០០%** | **៥៨៤.២៦៥** | **១០០%** |

ចំណូលសរុបចំនួន ៦៥៦,៨៩ ប៊ីលានរៀល ក្នុងត្រីមាសទី៣ ឆ្នាំ២០២១ ភាគច្រើនបានមកពីចំណូលការប្រាក់ដែលមានចំណែក ៩០,៦៣% នៃចំណូលសរុប និងចំណូលសរុបបានកើនឡើងចំនួន ៧២,៦៥ ប៊ីលានរៀល ឬ ១២,៤៣% បើប្រៀបធៀបទៅនឹងចំណូលសរុបក្នុងត្រីមាសទី៣ ឆ្នាំ២០២០។

### ៣- ការវិភាគគម្លាតចំណេញដុល

របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី បានរៀបចំក្នុងទម្រង់ជារបាយការណ៍ដែលមិនបង្ហាញពីគម្លាតចំណេញដុលទេ។ ចំណូលការប្រាក់សុទ្ធដែលទទួលបានមកពីចំណូលការប្រាក់សរុបដកនឹងចំណាយការប្រាក់សរុប នឹងត្រូវយកមកបង្ហាញនៅក្នុងការវិភាគចំណេញ/(ខាត) មុនបង់ពន្ធ ដូចខាងក្រោម។

## ៤- ការវិភាគចំណេញ/(ខាត) មុនបង់ពន្ធ

| របាយការណ៍ចំណេញ ឬខាត (លានរៀល) | ត្រីមាសទី៣ ឆ្នាំ២០២១ | ត្រីមាសទី៣ ឆ្នាំ២០២០ | គម្លាត | |
|---|---|---|---|---|
| | | | ចំនួន | ភាគរយ |
| ចំណូលការប្រាក់ | ៥៩៥.៣៦៨ | ៥២៣.៥១១ | ៧១.៨៥៧ | ១៣,៧៣% |
| ចំណាយការប្រាក់ | (១៨៧.៥៩៤) | (១៥៧.៨៩១) | (២៩.៧០៣) | ១៩,៤៣% |
| **ចំណូលការប្រាក់សុទ្ធ** | **៤១២.៧៧៤** | **៣៧០.៦២០** | **៤២.១៥៤** | **១១,៣៧%** |
| ចំណូលកម្រៃ និងជើងសា | ៤២.៦៧៥ | ៤៦.៥៤៨ | (៣.៨៧៣) | -៨,៣២% |
| ចំណាយកម្រៃ និងជើងសា | (១.៦៧០) | (២.២៨៦) | ៦១៦ | -២៦,៩៥% |
| **ចំណូលកម្រៃ និងជើងសាសុទ្ធ** | **៤១.០០៥** | **៤៤.២៦៣** | **(៣.២៥៨)** | **-៧,៣៦%** |
| ការខាតបង់ឱនភាពនៃតម្លៃរបស់ឥណទាននិងបុរេប្រទាន ប្រាក់បញ្ញើនៅធនាគារផ្សេងៗ និងគណនីត្រូវទទួលផ្សេងៗ | (៣៣.៩៤៨) | (៣២.៥៤៨) | (១.៤០០) | ៤,៣០% |
| ការខាតបង់ឱនភាពនៃតម្លៃកិច្ចសន្យាក្រៅតារាងតុល្យការ | (៤) | (៦២១) | ៦១៧ | -៩៩,៣៦% |
| **ចំណាយសុទ្ធពីការខាតបង់ឱនភាពនៃតម្លៃ** | **(៣៣.៩៥១)** | **(៣៣.១៦៩)** | **(៧៨២)** | **២,៣៦%** |
| **ចំណូលបន្ទាប់ពីខាតបង់ឱនភាពនៃតម្លៃសុទ្ធ** | **៤១៩.៨២៧** | **៣៨១.៧១៤** | **៣៨.១១៣** | **៩,៩៨%** |
| ចំណូលផ្សេងៗ | ១៨.៨៤៩ | ១៤.១៨៧ | ៤.៦៦២ | ៣២,៨៦% |
| ចំណាយទូទៅ និងរដ្ឋបាល | (២៤០.១៣៩) | (២១៥.២៣០) | (២៤.៩០៩) | ១១,៥៧% |
| **ចំណេញមុនចំណាយពន្ធលើប្រាក់ចំណេញ** | **១៩៨.៥៣៧** | **១៨០.៦៧១** | **១៧.៨៦៦** | **៩,៨៩%** |

ប្រាក់ចំណេញមុនបង់ពន្ធលើប្រាក់ចំណេញនៅត្រីមាសទី៣ ឆ្នាំ២០២១ បានកើនឡើងចំនួន ១៧,៨៧ ប៊ីលានរៀល ឬ ៩,៨៩% បើប្រៀបធៀបទៅនឹងត្រីមាសទី៣ ឆ្នាំ២០២០ ដោយសារការកើនឡើងនៃចំណូលការប្រាក់សុទ្ធចំនួន ៤២,១៥ ប៊ីលានរៀល ឬ ១១,៣៧% និងការកើនឡើងនៃចំណូលផ្សេងៗ ចំនួន ៤,៦៦ ប៊ីលានរៀល ឬ ៣២,៨៦% កាត់កងដោយការថយចុះនូវចំណូលកម្រៃ និងជើងសាសុទ្ធចំនួន ៣,២៦ ប៊ីលានរៀល ឬ ៧,៣៦% និងការកើនឡើងនូវចំណាយទូទៅ និងរដ្ឋបាលចំនួន ២៤,៩១ ប៊ីលានរៀល ឬ ១១,៥៧%។

## ៥- ការវិភាគចំណេញ/(ខាត) ក្នុងការិយបរិច្ឆេទ

| របាយការណ៍ចំណេញ ឬខាត (លានរៀល) | ត្រីមាសទី៣ ឆ្នាំ២០២១ | ត្រីមាសទី៣ ឆ្នាំ២០២០ | គម្លាត | |
|---|---|---|---|---|
| | | | ចំនួន | ភាគរយ |
| **ចំណេញមុនចំណាយពន្ធលើប្រាក់ចំណេញ** | **១៩៨.៥៣៧** | **១៨០.៦៧១** | **១៧.៨៦៦** | **៩,៨៩%** |
| ចំណាយពន្ធលើប្រាក់ចំណេញ | (៣៩.៨៤២) | (៣៨.៧២៥) | (១.១១៧) | ២,៨៨% |
| **ប្រាក់ចំណេញក្នុងការិយបរិច្ឆេទ** | **១៥៨.៦៩៥** | **១៤១.៩៤៦** | **១៦.៧៤៩** | **១១,៨០%** |

ប្រាក់ចំណេញក្នុងត្រីមាសទី៣ ឆ្នាំ២០២១នេះ ខ្ពស់ជាងត្រីមាសទី៣ ឆ្នាំ២០២០ ចំនួន ១៦,៧៥ ប៊ីលានរៀល ឬ ១១,៨០%។ ការកើនឡើងនេះ ភាគច្រើនបណ្តាលមកពីការកើនឡើងនូវចំណូលការប្រាក់សុទ្ធចំនួន ៤២,១៥ ប៊ីលានរៀល ស្មើនឹង ១១,៣៧% ធៀបនឹងត្រីមាសទី៣ ឆ្នាំ២០២០។

## ៦- ការវិភាគលទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ

| លទ្ធផលលម្អិតសរុប (លានរៀល) | ត្រីមាសទី៣ ឆ្នាំ២០២១ | ត្រីមាសទី៣ ឆ្នាំ២០២០ | គម្លាត | |
|---|---|---|---|---|
| | | | ចំនួន | ភាគរយ |
| **ប្រាក់ចំណេញក្នុងការិយបរិច្ឆេទ** | **១៥៨.៦៩៥** | **១៤១.៩៤៦** | **១៦.៧៤៩** | **១១,៨០%** |
| **លទ្ធផលលម្អិតផ្សេងៗ៖** | | | | |
| **ធាតុដែលនឹងមិនត្រូវបានចាត់ថ្នាក់ឡើងវិញទៅចំណេញ ឬខាត៖** | | | | |
| ការវាស់វែងឡើងវិញនៃកាតព្វកិច្ចអត្ថប្រយោជន៍និយោជិត | ៤៣៩ | ៤៧៩ | (៤០) | -៨,៣៥% |
| **ធាតុដែលត្រូវ ឬអាចត្រូវបានចាត់ថ្នាក់ឡើងវិញនៅគ្រាបន្ទាប់ទៅចំណេញ ឬខាត៖** | | | | |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | ៩៥៤ | ១.២៩២ | (៣៣៨) | -២៦,១៦% |
| **លទ្ធផលចំណេញ/(ខាត)លម្អិតផ្សេងៗក្នុងការិយបរិច្ឆេទ** | **១.៣៩៣** | **១.៧៧១** | **(៣៧៨)** | **-២១,៣៤%** |
| **លទ្ធផលលម្អិតសរុបក្នុងការិយបរិច្ឆេទ** | **១៦០.០៨៨** | **១៤៣.៧១៧** | **១៦.៣៧១** | **១១,៣៩%** |

## ៧- ការវិភាគពីកត្តា និងនិន្នាការដែលប៉ះពាល់ស្ថានភាព និងលទ្ធផលហិរញ្ញវត្ថុ

កំណើនអត្រាចាក់វ៉ាក់សាំងកូវីដ-១៩ នៅព្រះរាជាណាចក្រកម្ពុជាអាចបង្កើតបាននូវភាពស៊ាំសហគមន៍នៅទូទាំងកម្ពុជាដើម្បីទប់ទល់នឹងការឆ្លងរាលដាលនៃជំងឺកូវីដ-១៩។ ដោយមើលឃើញពីប្រសិទ្ធភាពនៃវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ កាន់តែប្រសើរឡើង រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចបើកឲ្យដំណើរការអាជីវកម្ម និងបើកប្រទេសកម្ពុជាឡើងវិញជាបណ្តើរៗ និងតាមដំណាក់កាលជាមួយនឹងភាពប្រយ័ត្នប្រយែង និងការទទួលខុសត្រូវខ្ពស់ តាមគន្លងប្រក្រតីភាពថ្មី។ រាជរដ្ឋាភិបាលបានកែប្រែលក្ខខណ្ឌនៃការធ្វើចត្តាឡីស័កដោយសារជំងឺកូវីដ-១៩ ដោយកាត់បន្ថយរយៈពេលដល់មន្ត្រីកម្ពុជា អ្នកការទូត និងគណៈប្រតិភូបរទេស អ្នកវិនិយោគ និងអ្នកធ្វើដំណើរចូលទូទៅ ប្រសិនបើពួកគេត្រូវបានចាក់វ៉ាក់សាំងពេញលេញ។ នេះជាសញ្ញាមួយបានបង្ហាញថាសកម្មភាពសេដ្ឋកិច្ចនឹងកាន់តែមានកំណើនខ្លាំងចាប់ពីចុងឆ្នាំ២០២១ ដោយសារប្រសិទ្ធភាពនៃវ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ដែលបានដាក់ឲ្យប្រើប្រាស់នៅទូទាំងពិភពលោក។

ទោះបីជាមានការរីករាលដាលនៃជំងឺកូវីដ-១៩ ឆ្លងចូលក្នុងសហគមន៍ក្នុងព្រះរាជាណាចក្រកម្ពុជា នៅអំឡុងឆ្នាំ២០២១ក្តី ក៏ធនាគារនៅតែបន្តពង្រីកសេវាស្វ័យប្រតិបត្តិការរបស់ខ្លួន ដើម្បីលើកកម្ពស់សមត្ថភាពក្នុងការឆ្លើយតបនឹងការវិវឌ្ឍបច្ចេកវិទ្យាចុងក្រោយបំផុត ឲ្យកាន់តែមានភាពងាយស្រួល រហ័សទាន់ចិត្ត សុវត្ថិភាពខ្ពស់ និងទទួលបានការគាំទ្រពីសាធារណជនគ្រប់មជ្ឈដ្ឋាន។ រូបរាងថ្មីនៃ **អេស៊ីលីដាម៉ូបាល** ជួយឲ្យអតិថិជនអាចធ្វើប្រតិបត្តិការធនាគារតាមអនឡាញបានកាន់តែងាយស្រួល នៅគ្រប់ទីកន្លែង និងគ្រប់ពេលវេលា។ ការចូលរួមរបស់អតិថិជនរបស់យើងក្នុងការប្រើប្រាស់សេវាស្វ័យប្រតិបត្តិការធនាគារ គឺមិនត្រឹមតែបានបង្ហាញអំពីការផ្លាស់ប្តូរឥរិយាបថរបស់ពួកគាត់ក្នុងការប្រើប្រាស់សេវាកម្មតាមបែបប្រពៃណីប៉ុណ្ណោះទេ ក៏ប៉ុន្តែថែមទាំងបានបង្ហាញអំពីការចូលរួមក្នុងការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ជាមួយនឹងរាជរដ្ឋាភិបាល ក៏ដូចជាក្រសួងសុខាភិបាលផងដែរ។

## ខ- កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ

### ១- ការវិភាគពីលក្ខខណ្ឌនៃតម្រូវការ និងការផ្គត់ផ្គង់

ធនាគារ អេស៊ីលីដា ទទួលបានជោគជ័យនៅលើទីផ្សារដែលនាំមកនូវផលចំណេញអាស្រ័យដោយកត្តាពីរគឺ៖

- កំណើនសំពៀតឥណទាន ដោយសារតម្រូវការខ្ពស់នៅលើទីផ្សារលើផលិតផលឥណទានរបស់ធនាគារ ជាពិសេសវិស័យ SME។
- កំណើនប្រាក់បញ្ញើ-សន្សំ របស់ធនាគារ រួមជាមួយផលិតផល និងសេវាកម្មផ្សេងទៀត។

កត្តាទាំងពីរនេះត្រូវបានផ្សារភ្ជាប់ជាមួយនឹងការអភិវឌ្ឍឥតឈប់ឈរនៃប្រព័ន្ធឌីជីថលរបស់ធនាគារ ដែលផ្តល់ជូនអតិថិជននូវផលិតផល និងសេវាកម្មហិរញ្ញវត្ថុប្រកបដោយភាពច្នៃប្រឌិត និងទាន់សម័យ។

ធនាគារ អេស៊ីលីដា ភីអិលស៊ី កំពុងតែអភិវឌ្ឍនូវហេដ្ឋារចនាសម្ព័ន្ធឲ្យកាន់តែទូលំទូលាយសម្រាប់ជាជម្រើសដ៏សម្បូរបែបជាមួយនឹងការិយាល័យទាំង៣១៩ តាមរយៈការផ្លាស់ប្តូរបន្តិចម្តងៗទៅជាមជ្ឈមណ្ឌលដែលអាចធ្វើស្វ័យប្រតិបត្តិការដែលមានទីតាំងធនាគារស្វ័យប្រវត្តិចំនួន១៧ ព្រមទាំងមាន**ម៉ាស៊ីនអេធីអឹមអេស៊ីលីដា**ចំនួន៩២៥គ្រឿង និងម៉ាស៊ីនឆូតកាតចំនួន៤.៣៥៧គ្រឿង។ ចំណុចគួរជាទីមោទកភាពគឺធនាគារ អេស៊ីលីដា បានបោះពុម្ពប័ណ្ណ**អេធីអឹមអេស៊ីលីដា**ចំនួន១,៥១លានប័ណ្ណជូនដល់អតិថិជន។ បន្ថែមលើនេះ **អេស៊ីលីដាម៉ូបាល** បានទទួលប្រជាប្រិយភាពយ៉ាងខ្លាំងដែលមានអ្នកចុះឈ្មោះប្រើប្រាស់ច្រើនជាង២,១៦លាននាក់ នៅដំណាច់ខែកញ្ញា ឆ្នាំ២០២១នេះ។

ការបង្កើនភាពងាយស្រួលដល់អតិថិជន និងពង្រឹងប្រព័ន្ធសុវត្ថិភាពអ៊ិនធើណែត គឺជាចំណុចដែលធនាគារ អេស៊ីលីដា ផ្តោតការយកចិត្តទុកដាក់បំផុត។ ដើម្បីសម្រេចនូវវឌ្ឍនភាពគោលដៅដ៏រឹងមាំទាំងនេះ ធនាគារនឹងបន្តលើកកម្ពស់ហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មាន តាមរយៈការវិនិយោគលើបច្ចេកវិទ្យាទំនើបចុងក្រោយ ពង្រឹងសមត្ថភាពធនធានមនុស្ស ព្រមទាំងពង្រីកនិងកែលម្អដំណើរការអាជីវកម្ម។ ជាយុទ្ធសាស្ត្រ ធនាគារកំពុងអភិវឌ្ឍប្រព័ន្ធទូទាត់ដែលអាចឱ្យដៃគូទាំងក្នុង និងក្រៅប្រទេសអាចភ្ជាប់ប្រព័ន្ធនេះដើម្បីបម្រើអតិថិជនទៅវិញទៅមក និងឆ្លងព្រំដែន។ ប្រព័ន្ធនេះមិនត្រឹមតែផ្តល់អត្ថប្រយោជន៍ដោយផ្ទាល់ដល់អតិថិជនដ៏ឆ្លាតវៃរបស់យើងប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងដៃគូអាជីវកម្មរបស់ពួកគាត់ផងដែរ។ យើងខ្ញុំទទួលស្គាល់ថាអតិថិជន និងដៃគូអាជីវកម្មទាំងអស់គឺជាបណ្តាញតភ្ជាប់ដ៏មានសារសំខាន់សម្រាប់ពង្រីកសេវាកម្មរបស់ធនាគារ និងរីកចម្រើនជាមួយគ្នា។

**អេស៊ីលីដាម៉ូបាល** បានកែលម្អយ៉ាងទូលំទូលាយ និងផ្លាស់ប្តូររូបរាងថ្មី កាន់តែទំនើប ងាយស្រួល និងមានសុវត្ថិភាពខ្ពស់ ជាមួយនឹងមុខងារពិសេសៗជាច្រើន ។ ឥឡូវនេះ អតិថិជនទាំងអស់អាចប្រតិបត្តិការប្រាក់បញ្ញើ-សន្សំ (សំចៃ ចរន្ត និងមានកាលកំណត់) តាមរយៈ **អេស៊ីលីដាម៉ូបាល** បានភ្លាមៗ ថែមទាំងទទួលបានការប្រាក់ខ្ពស់ទៀតផង។ លោកអ្នកក៏អាចដាក់ប្រាក់បញ្ញើមានកាលកំណត់ដោយខ្លួនឯងបានយ៉ាងងាយស្រួល ជាមួយម៉ាស៊ីនដាក់ប្រាក់បញ្ញើមានកាលកំណត់ផងដែរ។

ធនាគារក៏បាន និងកំពុងបន្តវិនិយោគក្នុងការពង្រីកទីតាំងស្វ័យសេវាធនាគារ ដោយធ្វើការដំឡើងបន្ថែមនូវ **ម៉ាស៊ីនអេធីអឹមអេស៊ីលីដា** ម៉ាស៊ីនដក-ដាក់ប្រាក់ ម៉ាស៊ីនបើកគណនីនិងបោះពុម្ពប័ណ្ណអេធីអឹម ម៉ាស៊ីនដាក់ប្រាក់បញ្ញើមានកាលកំណត់ ម៉ាស៊ីនឆូតកាត និងការពង្រីកបណ្តាញទូទាត់តាម **ឃ្យូអរកូដ** របស់ខ្លួន។

ដើម្បីផ្តល់នូវភាពងាយស្រួលជាងមុនជូនដល់អ្នកប្រើប្រាស់ក្នុងការធ្វើប្រតិបត្តិការទូទាត់ថ្លៃទំនិញ និងសេវាកម្មផ្សេងៗប្រកបដោយប្រសិទ្ធភាព សុវត្ថិភាព និងទំនុកចិត្តខ្ពស់តាម KHQR រវាងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ដែលជាសមាជិករបស់កម្មវិធីបាគង (Bakong App)។

ដើម្បីគាំទ្រដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ (ក្នុងអំឡុងពេលនៃការរីករាលដាលជាសកលនៃជំងឺកូវីដ-១៩) ឱ្យមានសន្ទនីយភាពបន្ថែមទៀតដើម្បីឆ្លើយតបទៅនឹងតម្រូវការទុនរបស់ខ្លួន ធនាគារជាតិ នៃ កម្ពុជា បានបន្ធូរបន្ថយអនុបាតមួយចំនួនដូចជា៖ សាធនភាព

ទូទាត់ដើមទុន ប្រាក់បម្រុងកាតព្វកិច្ច។ល។ ហើយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានកាត់បន្ថយពន្ធកាត់ទុកលើការប្រាក់កម្ចី ក៏ដូចជាបង្កើតសន្ទនីយភាពបន្ថែមទៀតនៅលើទីផ្សារដែលមានថ្លៃដើមទាប។ កត្តាទាំងនេះបានផ្តល់ឱកាសសម្រាប់ការប្រកួតប្រជែងថ្លៃ ដែលអាចប៉ះពាល់ដល់ចំណូលរបស់ធនាគារក្នុងរយៈពេលខ្លី ប៉ុន្តែវានឹងជួយឱ្យមានភាពរឹងមាំសម្រាប់រយៈពេលវែង។

## ២- ការវិភាគពីការឡើងចុះនៃថ្លៃវត្ថុធាតុដើម

ធនាគារ អេស៊ីលីដា ភីអិលស៊ី ប្រតិបត្តិការក្នុងវិស័យសេវាកម្ម ដែលការឡើងចុះនៃថ្លៃវត្ថុធាតុដើមមិនអាចអនុវត្តបានចំពោះធនាគារឡើយ។

## ៣- ការវិភាគលើពន្ធ

ធនាគារ អេស៊ីលីដា ភីអិលស៊ី និងក្រុមហ៊ុនបុត្រសម្ព័ន្ធ ស្ថិតនៅក្រោមច្បាប់ស្តីពីពន្ធដារនៃប្រទេសនីមួយៗ ដូច្នេះធនាគារ និងក្រុមហ៊ុនបុត្រសម្ព័ន្ធមានកាតព្វកិច្ចបង់ពន្ធតាមការកំណត់របស់អាជ្ញាធរពន្ធដារនីមួយៗ។

ការបង់ពន្ធជូនអគ្គនាយកដ្ឋានពន្ធដារមិនត្រឹមតែជាកាតព្វកិច្ច និងការទទួលបានវិញ្ញាបនបត្រអនុលោមភាពសារពើពន្ធប្រភេទ **“មាស”** ពីអគ្គនាយកដ្ឋានពន្ធដារសម្រាប់ឆ្នាំជាប់ពន្ធ ២០២០ ដល់ ២០២១ ប៉ុណ្ណោះទេ ប៉ុន្តែជាការចូលរួមចំណែកក្នុងសង្គម និងកំណើនសេដ្ឋកិច្ចផងដែរ។

ចំណូលពន្ធគឺជាប្រភពចំណូលដ៏សំខាន់បំផុតសម្រាប់ប្រទេស។ រដ្ឋាភិបាលប្រមូលពន្ធកាន់តែច្រើន ការចូលរួមវិភាគទានកាន់តែច្រើនដល់ការអភិវឌ្ឍប្រទេស។ ធនាគារ អេស៊ីលីដា ភីអិលស៊ី ជាធនាគារដែលបានបង់ពន្ធដារច្រើនបំផុតលំដាប់ទី៤ ក្នុងចំណោមអ្នកបង់ពន្ធទាំងអស់ក្នុងឆ្នាំ២០២០។ ធនាគារ អេស៊ីលីដា ភីអិលស៊ី មានមោទកភាពដែលអាចចូលរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាយើង។

## ៤- ការវិភាគលើធាតុដែលខុសពីធម្មតា និងធាតុវិសាមញ្ញ

ធនាគារមិនមានធាតុ ប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលខុសពីធម្មតាជាសារវន្តនោះទេ។ ទោះជាយ៉ាងណាក៏ដោយ លក្ខខណ្ឌសេដ្ឋកិច្ចដែលបានរងផលប៉ះពាល់ដោយសារការរីករាលដាលនៃជំងឺកូវីដ-១៩ ជាពិសេសវីរុសកូវីដ-១៩បំប្លែងថ្មី ឆ្លងចូលក្នុងសហគមន៍ក្នុងព្រះរាជាណាចក្រកម្ពុជាក្នុងឆ្នាំ២០២១នេះ អាចជះឥទ្ធិពលដល់សមត្ថភាពសងត្រលប់មកវិញរបស់អតិថិជន ដែលគុណភាពឥណទានរបស់ធនាគារអាចរងផលប៉ះពាល់បន្តិចបន្តួច។

# គ- ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល

ដើម្បីចូលរួមគាំទ្រការរីកលូតលាស់អាជីវកម្មរបស់អតិថិជន ធនាគារ អេស៊ីលីដា ភីអិលស៊ី បានបញ្ចុះអត្រាការប្រាក់លើការស្នើសុំឥណទានថ្មីគ្រប់ប្រភេទ និងដោយកាន់តែមានភាពងាយស្រួល អតិថិជនទាំងអស់អាចដាក់សំណើសុំឥណទានតាមរយៈ **អេស៊ីលីដា ម៉ូបាល**។ ជាលទ្ធផល សមតុល្យឥណទានដុលសរុបនៅត្រីមាសទី៣ ឆ្នាំ២០២១ មានការកើនឡើងចំនួន ២,៣៣២ ទ្រីលានរៀល ស្មើនឹង ១២,៧៥% ធៀបនឹងដំណាច់ឆ្នាំ២០២០។

# ឃ- ផលប៉ះពាល់នៃការប្តូររូបិយប័ណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ

ក្នុងត្រីមាសទី៣ ឆ្នាំ២០២១ អត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិក បានធ្លាក់ចុះបន្តិចបើធៀបនឹងត្រីមាសមុនដោយសារផលប៉ះពាល់នៃការអូសបន្លាយការរីករាលដាលនៃជំងឺកូវីដ-១៩ នាំឲ្យលំហូរចូលនៃប្រាក់ដុល្លារអាមេរិកតាមរយៈភ្ញៀវទេសចរអន្តរជាតិ និងការវិនិយោគផ្ទាល់ពីបរទេសមានការថយចុះ និងការថយចុះខ្លះនៃតម្រូវការប្រាក់រៀល ស្របជាមួយនឹងស្ថានភាពយឺតយ៉ាវនៃអាជីវកម្មមួយចំនួន។ តម្លៃរបស់ប្រាក់រៀលបានស្ថិតនៅចន្លោះពី ៤.០៩៦ ទៅ ៤.១២៣ ក្នុងមួយដុល្លារ (រយៈពេលដូចគ្នាកាលពីឆ្នាំមុនមានចន្លោះពី ៤.០៧៥ ទៅ ៤.១០៩ ក្នុងមួយដុល្លារ)។ តែការផ្លាស់ប្តូរទាំងនេះ ស្ថិតនៅក្នុងកម្រិតប្រែប្រួលធម្មតាប៉ុណ្ណោះ។ ចំពោះធនាគារ អេស៊ីលីដា ភីអិលស៊ី គឺបានអនុវត្តយ៉ាងម៉ឺងម៉ាត់តាមបទប្បញ្ញត្តិ និងគោលនយោបាយផ្ទៃក្នុងធនាគារ

ទាក់ទងទៅនឹងស្ថានភាពចំហសុទ្ធនៃរូបិយប័ណ្ណ។ អាស្រ័យហេតុនេះ ផលប៉ះពាល់ពីការប្រែប្រួលអត្រាប្តូរប្រាក់លើអាជីវកម្មធនាគារមានតិចតួចបំផុត។ ផលប៉ះពាល់នេះត្រូវបានវាស់វែង តាមដាន និងគ្រប់គ្រងជាប្រចាំថ្ងៃ ដើម្បីចាត់វិធានការដោះស្រាយបានទាន់ពេលវេលាតាមការចាំបាច់។

ចំណែកឯអត្រាការប្រាក់បញ្ញើ និងប្រាក់កម្ចី គឺមិនមានការប្រែប្រួលគួរឱ្យកត់សម្គាល់ឡើយ។ ជាមួយគ្នានោះដែរ ធនាគារបានដំណើរការអាជីវកម្មរបស់ខ្លួនដោយផ្អែកលើរបបអត្រាការប្រាក់ថេរ (ទាំងប្រាក់បញ្ញើ និងប្រាក់កម្ចី) ដែលមិនមានទំនាក់ទំនងផ្ទាល់ជាមួយចលនាអត្រាការប្រាក់នៅក្នុងទីផ្សារហិរញ្ញវត្ថុអន្តរជាតិឡើយ។ ចំពោះទីផ្សារក្នុងស្រុកវិញមានការប្រែប្រួលអត្រាការប្រាក់តិចតួចដោយសារការប្រកួតប្រជែងតម្លៃទីផ្សារ។ ដូច្នេះផលប៉ះពាល់នៃការប្រែប្រួលអត្រាការប្រាក់លើអាជីវកម្មរបស់ធនាគារគឺតិចតួចបំផុត ហើយការប្រែប្រួលនោះស្ថិតក្នុងការរំពឹងទុក និងការត្រួតពិនិត្យ។ លើសពីនេះហានិភ័យអត្រាការប្រាក់ត្រូវបានវាស់វែងតាមដាន និងចាត់ចែងជាប្រចាំខែដើម្បីចាត់វិធានការដោះស្រាយទាន់ពេលវេលា ចៀសវាងបាននូវផលប៉ះពាល់ធ្ងន់ធ្ងរដល់លទ្ធផលនៃអាជីវកម្មរបស់ធនាគារ។

ធនាគារមិនបានធ្វើប្រតិបត្តិការជួញដូរនានាដែលមានទម្រង់ជាទំនិញ (Commodity) នោះទេ។

## ង- ផលប៉ះពាល់នៃអតិផរណា

ការព្យាករណ៍នៃអត្រាអតិផរណាសម្រាប់ឆ្នាំ ២០២១ នៅរក្សាដដែល នៅកម្រិត ៣.១% ។ ប្រតិបត្តិការរបស់ធនាគារមិនមានទំនាក់ទំនងខ្លាំងទៅនឹងកម្រិតអតិផរណាទេ ដូច្នេះផលប៉ះពាល់នៃអតិផរណាលើអាជីវកម្មរបស់ធនាគារមានតិចតួចបំផុត។

## ច- គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុ របស់រាជរដ្ឋាភិបាល

- <u>**គោលនយោបាយសេដ្ឋកិច្ច៖**</u>

រាជរដ្ឋាភិបាលកម្ពុជា កាលពីថ្ងៃទី១ ខែសីហា ឆ្នាំ២០២១ បានទម្លាក់តួលេខព្យាករណ៍កំណើន GDP របស់កម្ពុជា មកត្រឹម ២,៥% នៅឆ្នាំ២០២១ ពីតួលេខព្យាករណ៍កាលពីលើកមុនចំនួន ៤,១% ដោយសារផលប៉ះពាល់នៃជំងឺកូវីដ-១៩។ ជាមួយគ្នានេះ លោកឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានរំលឹកថា កំណើនសេដ្ឋកិច្ចរបស់កម្ពុជាត្រូវបានព្យាករពីលើកមុនថានឹងមានកំណើនក្នុងអត្រា ៤% ក្នុងឆ្នាំ ២០២១ បន្ទាប់ពីធ្លាក់ចុះអស់ ៣,១% ក្នុងឆ្នាំ ២០២០។ ក៏ប៉ុន្តែដោយសារឧប្បត្តិហេតុថ្ងៃទី២០ ខែកុម្ភៈ និងការរាតត្បាតថ្មីនៃវីរុសប្រភេទដែលតាផង កំណើននេះត្រូវបានបន្ទាបមកនៅត្រឹម ២,៤% ទៅវិញ។ លោកក៏បានលើកឡើងដែរថា កម្ពុជានឹងមានកំណើនសេដ្ឋកិច្ច ៤,៨% នៅឆ្នាំ២០២២ ដោយសារព្រះរាជាណាចក្រកម្ពុជាអាចស្តារសេដ្ឋកិច្ចឡើងវិញក្នុងពេលឆាប់ៗនេះ យោងទៅតាមយុទ្ធនាការចាក់ថ្នាំបង្ការដល់ប្រជាពលរដ្ឋ កសាងប្រព័ន្ធការពារនៅក្នុងសហគមន៍ និងជំរុញសង្គមឱ្យវិលមករកភាពប្រក្រតីឡើងវិញ។ [១]

ស្ថាប័នល្បីល្បាញមួយចំនួនក៏បានព្យាករអំពី GDP របស់កម្ពុជាផងដែរ ក្នុងនោះ ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) បានបន្ទាបតួលេខព្យាករណ៍របស់ខ្លួន ច្រើនជាងពាក់កណ្ដាលសម្រាប់កំណើនសេដ្ឋកិច្ចរបស់កម្ពុជានៅឆ្នាំនេះ ដោយបានទម្លាក់ មកនៅត្រឹម ១,៩% ពីតួលេខដែលបានព្យាករកំណើនកាលពីខែមេសាចំនួន ៤%។ ADB បានរក្សាតួលេខព្យាករណ៍នៅឆ្នាំក្រោយនៅដដែលដោយរំពឹងថានឹងមានកំណើន GDP ចំនួន ៥,៥%។ មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) បានថ្លែងថា ផលិតផលក្នុងស្រុកសរុបរបស់កម្ពុជានឹងកើនឡើង ២,២% នៅឆ្នាំនេះ ទាបជាងការព្យាករកាលពីគ្រាមុនដែលមានកំណើន ៤,២% ក្នុង១ឆ្នាំ ហើយនឹងបន្តកើនឡើងជាសន្សឹមៗ មកវិញរហូតដល់អត្រាមុនកើតមានវិបត្តិចំនួន ៦,៥% ក្នុងរយៈពេលពីរបីឆ្នាំបន្ទាប់។ តាមការវិភាគទៅលើការព្យាករថ្មីរបស់ធនាគារពិភពលោកក៏បានបង្ហាញផងដែរថា កំណើនសេដ្ឋកិច្ចរបស់កម្ពុជានៅឆ្នាំនេះនឹងធ្លាក់ចុះមកនៅត្រឹម ២,២% ប៉ុន្តែនឹងងើបឡើងមកវិញនៅត្រឹម ៤,៥% នៅឆ្នាំក្រោយ និង ៥,៥% នៅឆ្នាំ២០២៣។ [២], [៣], [៤], [៥], [៦]

- **គោលនយោបាយសារពើពន្ធ៖**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានគាំទ្រលើវិធានការដែលបានដាក់ចេញរបស់អគ្គនាយកដ្ឋានពន្ធដារ និងបានផ្តល់អនុសាសន៍សំខាន់ៗ ជាទិសដៅអនុវត្តបន្តសម្រាប់ឆ្នាំ ២០២១ រួមមាន៖ (១) ត្រូវយកចិត្តទុកដាក់ ពិនិត្យ និងសិក្សាលើលទ្ធភាពនៃការប្រមូលចំណូលដែលមានសក្តានុពលផ្សេងទៀត ដោយគិតគូរទាំងទិដ្ឋភាពចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធ ដើម្បីធានាបាននូវអនុលោមភាពសារពើពន្ធ និងការប្រមូលចំណូលឱ្យបានគ្រប់ជ្រុងជ្រោយ ក្នុងនោះប្រភពចំណូលពីវិស័យ E-Commerce, វិស័យប្រេងកាតដែលជាសក្តានុពលថ្មី, វិស័យធនធានរ៉ែ ព្រមទាំងវិស័យដែលមានសក្តានុពលមួយចំនួនទៀត។ (២) រៀបចំកែសម្រួលបទប្បញ្ញត្តិក្នុងការកំណត់និយមន័យសហគ្រាសធុនតូចនិងមធ្យម និងជំរុញសម្រួលលើកកម្ពស់សហគ្រាសធុនតូចនិងមធ្យមមកក្នុងប្រព័ន្ធ ក្នុងគោលដៅជំរុញកំណើន និងបង្កើតជាកាលានុវត្តភាពសេដ្ឋកិច្ច។ (៣) ពង្រឹងការចុះបញ្ជីពន្ធដារ និងជំរុញការបំពេញកាតព្វកិច្ចសារពើពន្ធសម្រាប់សហគ្រាសក្នុងវិស័យកាស៊ីណូ ដើម្បីធានាឱ្យបាននូវតម្លាភាពសារពើពន្ធ និងការគ្រប់គ្រងប្រមូលចំណូលពន្ធឱ្យបានជាអតិបរមា។ (៤) បន្តអនុវត្តកំណែទម្រង់ស្ថាប័ន ទំនើបកម្មរដ្ឋបាលសារពើពន្ធ-ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដោយធានាយ៉ាងណាបង្កភាពងាយស្រួល (User Friendly) សម្រាប់អ្នកជាប់ពន្ធ និងមន្ត្រីព្រមទាំងពង្រឹងអនុលោមភាពសារពើពន្ធ ដើម្បីជំរុញប្រសិទ្ធភាព និងភាពប្រទាក់ក្រឡាក្នុងការបំពេញបេសកកម្មគ្រប់គ្រងប្រមូលចំណូលពន្ធ។ (៥) បន្តអនុវត្តប្រកបដោយការយកចិត្តទុកដាក់នូវយុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣ របស់រាជរដ្ឋាភិបាល។ (៦) បន្តពង្រឹងការអនុវត្តឱ្យមានប្រសិទ្ធភាពនូវការចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន (IT Platform) ស្របតាមខ្លឹមសារអនុក្រឹត្យលេខ ៨៤ អនក្រ.បក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២០ ។ (៧) ពង្រឹងនិងយកចិត្តទុកដាក់លើការធ្វើសវនកម្ម ស្របតាមខ្លឹមសារប្រកាសលេខ ២៧០ សហវ.ប្រក ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៩ ស្តីពីសវនកម្មពន្ធដារ ដែលជាជញ្ជីងវាស់នូវអនុលោមភាពរបស់សហគ្រាស និងចៀសវាងការបង្កការលំបាកដល់អ្នកជាប់ពន្ធ ។ (៨) បន្តលើកកម្ពស់និងបញ្ជ្រាបវប្បធម៌បង់ពន្ធ ពង្រឹងការផ្សព្វផ្សាយ និងអនុវត្តបទប្បញ្ញត្តិថ្មីពាក់ព័ន្ធនឹងពន្ធដារ ជូនដល់មន្ត្រីអនុវត្តផ្ទាល់ អ្នកជាប់ពន្ធ និងសាធារណជន ដើម្បីពន្យល់ និងដោះស្រាយការលំបាក និងចម្ងល់របស់ប្រជាពលរដ្ឋ។ (៩) បន្តកិច្ចសហការ និងពិគ្រោះយោបល់ ជាមួយវិស័យពាក់ព័ន្ធ ដើម្បីទទួលយកធាតុចូលក្នុងការសិក្សារៀបចំ និងកែលម្អ បទប្បញ្ញត្តិពាក់ព័ន្ធចាំបាច់នានា។ [៧]

សរុបរយៈពេល៩ខែ ឆ្នាំ២០២១ ចំណូលពន្ធ-អាករដែលអគ្គនាយកដ្ឋានពន្ធដារប្រមូលបាន (តាមប្រព័ន្ធគ្រប់គ្រងចំណូលអនឡាញរបស់អគ្គនាយកដ្ឋានពន្ធដារ) មានចំនួន ៨.៥៤៩,៩០ប៊ីលានរៀល (ប្រមាណជា ២.១១១,០៩លានដុល្លារអាមេរិក) ស្មើនឹង ៩៤,១២% នៃផែនការច្បាប់ហិរញ្ញវត្ថុសម្រាប់គ្រប់គ្រងឆ្នាំ២០២១ ធៀបនឹងចំណូលពន្ធ-អាករក្នុងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២០ ថយចុះចំនួន ៥៥០,២២ប៊ីលានរៀល (ប្រមាណជា ១៣៥,៨៦លានដុល្លារអាមេរិក) ឬស្មើនឹង -៦,០៥%។ [៨]

- **គោលនយោបាយរូបិយវត្ថុ៖**

ដើម្បីរួមចំណែកគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការស្តារកំណើនសេដ្ឋកិច្ច ធនាគារជាតិ នៃ កម្ពុជា បានកំណត់គោលនយោបាយរូបិយវត្ថុចំនួន៤ សម្រាប់អនុវត្តនៅឆ្នាំ២០២១ រួមមាន៖ (១) ការគ្រប់គ្រងការផ្គត់ផ្គង់រូបិយវត្ថុឲ្យស្ថិតក្នុងកម្រិតសមស្រប (២) រក្សាស្ថិរភាពអត្រាប្តូរប្រាក់ ដើម្បីរួមចំណែកស្ថិរភាពថ្លៃ និងជំនឿទុកចិត្តរបស់សាធារណជន (៣) លើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលតាមយន្តការទីផ្សារ និង (៤) ជំរុញការអភិវឌ្ឍទីផ្សារអន្តរធនាគារតាមរយៈការបង្កើនឧបករណ៍គោលនយោបាយរូបិយវត្ថុចាំបាច់ ក្នុងគោលដៅលើកកម្ពស់ប្រសិទ្ធភាពគោលនយោបាយរូបិយវត្ថុ។

សម្រាប់ឆមាសទី១នេះ រូបិយវត្ថុទូទៅ (M2) ត្រូវបានប៉ាន់ចាកើនឡើង ១៩% ខ្ពស់ជាងកំណើនក្នុងគ្រាដូចគ្នាក្នុងឆ្នាំមុន (១២,៣%) ដែលគាំទ្រជាចម្បងដោយកំណើនប្រាក់បញ្ញើជារូបិយប័ណ្ណចំនួន ១៧,២% កើនឡើង ៩,២% កំណើនរូបិយវត្ថុក្នុងចរាចរណ៍ចំនួន ២៧,១% កើនឡើង ២៨% និងកំណើនប្រាក់បញ្ញើជារៀលចំនួន ៣១% កើនឡើង ៣៨,២% បើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន ព្រមទាំងការបញ្ចេញសន្ទនីយភាពទៅក្នុងសេដ្ឋកិច្ច តាមរយៈការធ្វើប្រតិបត្តិការ LPCO ចំនួន ១២លើក ដោយបានផ្តល់សន្ទនីយភាពជារៀលចំនួន ៣,២ ទ្រីលានរៀល (៧៨៨ លានដុល្លារអាមេរិក) កើនឡើង ១២,៩%។ ឆ្លើយតបនឹងតម្រូវការ និងដើម្បីគ្រប់គ្រងសម្ពាធលើអត្រាប្តូរប្រាក់ ធនាគារជាតិ នៃ កម្ពុជា បានធ្វើអន្តរាគមន៍លក់ប្រាក់ដុល្លារអាមេរិកសុទ្ធដល់ទីផ្សារប្រមាណ ៤៨,៥លានដុល្លារអាមេរិក និងបានទិញប្រាក់ដុល្លារអាមេរិកសុទ្ធពីរដ្ឋាភិបាលចំនួន ២៦,៧លានដុល្លារអាមេរិក ហើយបានស្រូបសន្ទនីយភាពពីប្រព័ន្ធធនាគារវិញ តាមរយៈការចេញផ្សាយមូលបត្រអាចជួញដូរបាន (NCD) សរុបចំនួន ៦៧,៣

ទ្រីលានរៀល (ស្មើនឹង ១៦,៦ប៊ីលានដុល្លារអាមេរិក) កើនឡើង ១៧,៦% ក្នុងនោះ NCD ជាប្រាក់រៀលមានចំនួន ៧,៣ ទ្រីលានរៀល កើនឡើង ៣៣,៤% និង NCD ដុល្លារអាមេរិកមានចំនួន ១៤,៨ប៊ីលានដុល្លារអាមេរិកកើនឡើង ១៥,៩%។ [៩]

ឯកសារយោង:


(១) https://www.khmertimeskh.com/50918131/economic-growth-projected-at-4-8-percent-in-2022-deputy-pm/

(២) https://www.khmertimeskh.com/50939651/adb-slashes-kingdoms-gdp-forecast-to-1-9-due-to-covid/

(៣) https://m.phnompenhpost.com/business/imf-pins-2021-economic-growth-2

(៤) http://www.xinhuanet.com/english/asiapacific/2021-09/22/c_1310202907.htm

(៥) https://www.khmertimeskh.com/50944430/economy-will-grow-2-2-before-recovery-says-imf/

(៦) https://www.khmertimeskh.com/50944272/world-bank-forecasts-cambodias-economic-growth-down-to-2-2-percent/

(៧) https://dap-business.com/finance/2021/01/13/4567/

(៨) https://www.tax.gov.kh/u6rhf7ogbi6/gdtstream/81ba0994-a729-4baa-b04c-5dcf83c04e37

(៩) https://www.nbc.org.kh/download_files/publication/annual_rep_kh/Semi_Annual_Report_2021_Final.pdf


**ហត្ថលេខាអភិបាលរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ**

ថ្ងៃសុក្រ ១កើត ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០២១

បានអាន និងឯកភាព

ហត្ថលេខា

________________

**ឆាយ សឿន**

**ប្រធានក្រុមប្រឹក្សាភិបាល**

អេស៊ីលីដា
ACLEDA BANK